ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ការគំរាមកំហែង



នាមករណ៍ដោយ៖ នាម កាណាន់

បទគំរាមកំហែង

អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម ប្រឆាំងនឹងបុគ្គល កាលបើការ គំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬ សម្តែងចេញតាមលិខិត រូបភាព ឬ វត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

មាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ

បទគំរាមកំហែងដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ

ការគំរាមកំហែងក្រោមទម្រង់ណាក៏ដោយ ថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម ប្រឆាំងនឹងបុគ្គល ប្រសិនបើការគំរាមកំហែងនេះត្រូវបានធ្វើឡើងដោយមានបញ្ជាឱ្យបំពេញ លក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

មាត្រា ២៣២ នៃក្រមព្រហ្មទណ្ឌ

បទគំរាមកំហែងថានឹងសម្លាប់

ការគំរាមកំហែងថានឹងសម្លាប់ កាលបើការគំរាមកំហែងនេះធ្វើទ្បើងម្តងហើយ ម្តង ទៀត ឬ សម្តែងចេញតាមលិខិត រូបភាព ឬ វត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ

បទគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ហាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ

ការគំរាមកំហែងថានឹងសម្លាប់ក្រោមទម្រង់ណាក៏ដោយ ប្រសិនបើការគំរាមកំហែង នេះ ត្រូវបានធ្វើឡើងដោយមានបញ្ហាឱ្យ បំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០: (ប្រាំមួយលាន) រៀល ។

មាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌ

ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន ប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ (ត...)

មាត្រា ២៣៥ នៃក្រមព្រហ្មទណ្ឌ

ទោសបន្ថែម: ប្រភេទ និងរយៈពេល

(ត...)

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលយកមកប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិង គ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាបរយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុង សារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

មាត្រា ២៣៥ នៃក្រមព្រហ្មទណ្ឌ